ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករមូលបត្រកម្ពុជា
លេខ: ៤០/២៥ ន.ម.ក./ស.ប្រ.៣.

*ថ្ងៃពុធ ៥កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ គ.ស.២០២៥*

## សេចក្តីប្រកាសព័ត៌មាន

នាព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** លើកទី២៧ អាណត្តិទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** លើរបៀបវារៈចំនួន ៧ ដោយក្នុងនោះក៏មានផងដែរនូវការស្នើសុំអនុម័តលើសេចក្តីព្រាងប្រកាសស្តីពី "**ការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល**" របស់ **ន.ម.ក.**។ បន្ទាប់ពីធ្វើបទបង្ហាញជូនអង្គប្រជុំរួចមក អង្គប្រជុំបានពិភាក្សាផ្លាស់ប្តូរយោបល់ទាំងកម្រិតបច្ចេកទេស និងគោលនយោបាយលើរបៀបវារៈដែលបានរៀបចំដោយមន្ត្រីជំនាញ **ន.ម.ក.**។ ជាលទ្ធផល ក្រុមប្រឹក្សា **អ.ស.ហ.** បានអនុម័តលើសេចក្តីព្រាងប្រកាសស្តីពី "**ការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល**" របស់ **ន.ម.ក.**។ សេចក្តីព្រាងប្រកាសនេះ បានបែងចែកជា ៩ ជំពូក ៦៣ ប្រការ ដោយបានកំណត់ពីលក្ខខណ្ឌ និងនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណ បន្តអាជ្ញាបណ្ណ និងកាតព្វកិច្ចផ្សេងៗរបស់ក្រុមហ៊ុនផ្តល់សេវាទ្រព្យឌីជីថល ភ្នាក់ងារទ្រព្យឌីជីថល និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ក្នុងទិសដៅធានាឱ្យមាននូវសុច្ចរិតភាពទីផ្សារ តម្លាភាព សណ្តាប់ធ្នាប់ និងកិច្ចការពារវិនិយោគិន។ សេចក្តីព្រាងប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មទ្រព្យឌីជីថល ដែលមិនជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យឌីជីថលជាយន្តការនៃការទូទាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការអនុម័តលើសេចក្តីព្រាងប្រកាសស្តីពី"**ការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល**" របស់ **ន.ម.ក.** បានចូលរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ដោយស្របតាមការចង្អុលបង្ហាញផ្លូវដោយគោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ព្រមទាំងស្របតាមតម្រូវការចាំបាច់ចំពោះមុខសម្រាប់ការបន្តអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា។

**និយ័តករមូលបត្រកម្ពុជា**

អាសយដ្ឋាន : អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Address : Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@serc.gov.kh Website: www.serc.gov.kh